# ឱ! មហាភ្នំដងរែក

## អនុស្សាវរីយ៍ដ៏មហាខ្លោចផ្សាក្នុងរបបសម័យខ្មែរក្រហម



## ព្រះតេជគុណ អគ្គធីរោ លី ខាន់

ព្រះចៅអធិការ វត្ត ពន្លឺពុទ្ធចក្រ
ទីក្រុងឡូវែល, រដ្ឋម៉ាស្សាឈូសែត, សហរដ្ឋអាមេរិក
គ.ស. ១៩៨២ – ព.ស. ២៥២៥

រៀបចំចងក្រងបោះពុម្ពដោយ

**យឿន សំខាន់**

មេសា ២០០៩

# ឱ! មហាភ័យអាពត

## អនុស្សាវរីយ៍ដ៏មហាខ្លោចផ្សាក្នុងរបបសម័យខ្មែរក្រហម

*នមោនមស្សការលើកហត្ថាឱនសិរសី*
*គ្រានេះនឹងសម្តែងថ្លែងដំណាលពីព្រឹត្តិការណ៍*
*បង្គំរតនត្រៃដាក់តម្កល់លើសិរសា*
*ប្រវត្តិសាស្ត្រដ៏ខ្លោចផ្សារាស្ត្រកម្ពុជាត្រូវវេទនា ។*

*ជប់ប្រាំពីរមេសាមួយពាន់ប្រាំបួនរយចិតប្រាំ*
*ខ្មែរក្រហមវាសម្លាប់ស្លាប់រង្គាលគ្រប់ភូមិស្រុក*
*ប្រជារាស្ត្រត្រូវវេទនាជិតបួនឆ្នាំក្នុងនរក*
*ខ្លះសម្លាប់ទាំងទារកអស់ទាំងពូជគ្មានប្រណី ។*

*វារឹបអូសយកអស់ទ្រព្យរបស់ទាំងប៉ុន្មាន*
*ទីក្រុងស្ងាត់ជ្រងំផ្ទះធំៗ រុះហិនហែ*
*ស្លាបព្រានិងឆ្នាំងចានកាំបិតពូថៅកញ្ជើល្អី*
*ជម្លៀសរាស្ត្រទៅនៅព្រៃគាស់រានដីគ្រប់មណ្ឌល ។*

*វត្តអារាមយកធ្វើគុកឃុំអ្នកស្រុកធ្វើទោសពៃរ៍*
*ពុទ្ធរូបទាំងធំតូចវាវាយខ្ទេចអស់គ្មានសល់*
*គម្ពីរអត្ថបាលីចោលដាសដីតាមដើងថ្នល់*
*មន្ត្រីសង្ឃគ្រប់មណ្ឌលស្លាប់គ្មានសល់ដោយប្រល័យ។*

*ពង្រាត់អស់កុមារព្រាត់ប្រាសគ្នាពីម៉ែឪ*
*អ្នកខ្លះប្រាសច្រើនខួបមិនដែលជួបកូនប្រុសស្រី*
*បំបែកនាំយកទៅទុកឲ្យនៅស្ពានដទៃ*
*ទោះឈឺឬស្លាប់ក្តីក៏ឥតបីបានដឹងដែរ ។*

*ធ្វើការជាទម្ងន់ស៊ូអត់ធន់ព្រោះខ្លាចក្ស័យ*
*ស៊ីបបររាវកខ្វក់សោជាងជ្រូកអន់លើសឆ្កែ*
*វាវាយធាក់មនុស្សស្រីដែលមានផ្ទៃជិតគ្រប់ខែ*
*ម្ហូបអាហារច្រើនបន្លែស្ងោរតែផ្ទីនិងត្រកួន ។*

*ដាច់បបរបួនប្រាំថ្ងៃវាឲ្យស៊ីតែកន្ទក់*
*គ្មានកម្លាំងទៅធ្វើការចោរមោហាវារុកគួន*
*ហេវពេកដេកមិនលក់មុខស្លាំងស្ងក់ស្គមទាំងខ្លួន*
*ទំត្រដរលុះស្លាប់ខ្លួនប្រពន្ធកូននៅកំព្រា ។*

*ស្រីក្រមុំខូចរូបឆោមកាយទ្រុឌទ្រោមដូចជាយាយ*
*ជង្គង់ធំជាងភ្លៅក្បាលនោះកូវធំជាងស្មា*
*ប្រុសកម្លោះផងទាំងឡាយខ្លួនប្រែក្លាយដូចជាតា*
*ជ្រុះអស់ទាំងកេសាឈឺគ្រាំគ្រាជាទម្ងន់ ។*

*មុខហើមភ្នែកលឿងស្លេកគ្មានថ្នាំពេទ្យព្យាបាលរោគ*
*ដាច់ពោះស្លាប់ជិតអស់គ្មានស្រណោះប្រជាជន*
*ស្លាប់អស់ច្រើនគរគោករោគរាតត្បាតគ្រប់តំបន់*
*ហេវហត់ស្លាប់ទាន់ហន់កប់មិនទាន់រាល់ខែថ្ងៃ ។*

*ខ្លះខំគេចកៀសប្រាណវាចាប់បានវាយសម្លាប់*
*មួយរយរត់រួចមួយស្លាប់រង្វើយពាសពេញព្រៃ*
*ខ្លះត្រូវមីនផ្ទុះផាប់ខ្លះបាញ់ស្លាប់ជិតដែនថៃ*
*ពួកវាយាមរាល់ថ្ងៃចាំប្រល័យគ្រប់ទិសទី ។*

*រាស្រ្តត្រូវអន្តរធានស្លាប់រាល់លានដោយដៃទមិឡ*
*ចាប់ចងកាប់ផ្តាច់ផ្តិលឆ្អឹងដេរដាសពេញធរណី*
*ស្លាប់ដោយធ្វើការធ្ងន់ខ្លះស្លាប់ដោយគ្មានបាយស៊ី*
*អត់ម្ហូបឃ្លានពេញទីស៊ីកណ្តុរជាអាហារ ។*

*លុះឆ្នាំចិតប្រាំបួនយួនចូលវាយកំចាត់ទមិឡ*
*ខែមួយថ្ងៃប្រាំពីលទមិឡបោលចូលព្រៃព្រឹក្សា*
*ឯកឧត្តមហេងសំរិនឡើងគ្រប់គ្រងរដ្ឋកម្ពុជា*
*រាស្រ្តរាងចាលក៏នាំគ្នាភៀសអាត្មាចោលស្រុកស្រែ ។*

*ចូលដល់ព្រំដែនថៃចោរចង្រៃប្លន់យកអស់*
*មាសពេជ្រទ្រព្យរបស់គ្មានសល់សោះទាំងចិនខ្មែរ*
*ចោរសៀមវាវាយតប់ជ្រមុញទ្រូបលើក្ដីស្រែ*[1]
*ផែកខ្លួនគ្មានសល់ទេធេរហូតទ្វារតូចធំ ។*

*រួចផុតពីចោរប្លន់ចូលតំបន់ភូមិណងចាន*
*មិនអាចស្នាក់យូរបានសៀមសាមានវាដាក់ច្រំ*
*បញ្ជូនជនភៀសប្រាណរាប់រយឡានដោយបង្ខំ*
*ដឹកទៅដាក់នាជួរភ្នំព្រំដែនខេត្តព្រះវិហារ ។*

*លុះព្រឹកឡើងដេញឲ្យចុះបាញ់បង្រ្គះស្លាប់ច្រើនក្រៃ*
*ក្មេងចាស់ទាំងប្រុសស្រីនិងកូនខ្ចីស្លាប់ត្រៀបត្រា*
*ភិតភ័យខ្លាំងក្រៃលែងរត់ប្រដែងពារលើគ្នា*
*ដណ្តើមចុះពីបុព្វតាអន្ទះសារព្រោះខ្លាចក្ស័យ ។*

*ផ្លូវចុះភ្នំចោតចង្អៀតខំប្រជ្រៀតប្រពួនគ្នា*
*ប្រទោងឫស្សីរុក្ខាមែកព្រឹក្សាលតា*[2]*ព្រៃ*
*ទម្លាក់សំពាយចុះពួកប្រុសៗ លោតចុះខ្មី*
*ចាំទទួលយកកូនខ្ចីតពីដៃនៃមាតា ។*

*ចុះពីព្រឹកលុះរសៀលទើបដល់ក្នុងជ្រលងភ្នំ*
*សងខាងព្រៃជិតជុំភ្នំមួយគូទន្ទឹមគ្នា*
*ពួកខ្លះរកកាច់ឧសផ្ទុះគ្រាប់ស្លាប់ច្រើនមហិមា*
*ខ្លះស្វែងរកគង្គាជាន់ត្រូវមីនផ្ទុះស្លាប់ទៅ ។*

*ជនភៀសខ្លួនច្រើនម៉ឺននាក់ធ្លាក់នៅក្នុងភាពអាសន្ន*
*តក់ស្លុតភ័យស្មោស្មន់នឹកគុណព្រះ គុណម៉ែឪ*
*នឹងឆាកថយក្រោយវិញសៀមស្ទាក់បាញ់មិនឲ្យទៅ*
*នឹងទៅមុខឥតមានផ្លូវក្រាស់ដោយស្មៅនិងស្បូវភ្លាំង ។*

*ចុះទឹកជួបក្រពើឡើងទៅលើប្រទះខ្លា*
*ចូលព្រៃទាក់បន្លាឡើងរុក្ខាវាក់នឹងស្រាំង*
*គ្រានោះពួកចាមជ្វាហ៊ានពុះពារយ៉ាងក្លាខ្លាំង*
*បើកផ្លូវជាអាទិតាំងមីនផ្ទុះក្លាំងស្លាប់ត្រៀបត្រា ។*

*“ **ឱ! មហាភ្នំដងរែក** វែងអនេកជំស្កឹមស្កៃ*
*ដើមស្រឡៅខ្ពស់ត្រៃឈើត្រៃបែកព្រៃជ្រៃជន្ទា*
*សូរស័ព្ទរៃកណ្តឹងយំទ្រហឹងឆ្លើយឆ្លងគ្នា*
*ស្រណោះដល់ជនកម្ពុជាចរលើលាកំសត់ក្រៃ ។”*

---

[1] បានហុដោះយកខ្សែក្រវាត់មាសពីចង្កេះកែវអោយទៅសៀម ហើយចោរសៀមវាដាល់មួយដៃផ្កាប់មុខទៅនឹងក្ដីស្រែ ព្រោះវាខឹងដោយក្រអោយខ្សែក្រវាត់ទៅវា គឺថា បើវាមិនកំហែងយើងមិនអោយវា។

[2] លតាជាតិ ជាតិវល្លិ៍គ្រប់ប្រភេទតែងដុះវារឡើងដើមឈើ។

ដើររុកក្នុងព្រៃជ្រៅពារលើស្មៅស្បូវស្បាតក្រាស់    គ្រាប់មីនផ្ទុះច្រើនណាស់ត្រូវក្មេងចាស់ស្លាប់ពេញព្រៃ
អ្នកខ្លះត្រូវរបួសបាក់បែកអស់ទាំងជើងដៃ    ដេកស្ដូកបាត់ស្មារតីចាំតែថ្ងៃក្ស័យជីវា ។

ឯប្រពន្ធនិងកូនតូចស្បៀងក៏ហោចទ្រាំមិនបាន    ចោលប្ដីក្នុងស្មសានយំបោកប្រាណអន្ទះសា
នឹងនៅកំដរប្ដីគ្មានចំណីបរិភោគ្គា    ហើយខំកាត់ក្ដីមេត្តាចោលសង្សារទាំងអាល័យ ។

ពួកជនពនេចរខំត្រដរឆ្លងព្រៃភ្នំ    អត់បាយកូនវាយំឈឺរងឹងាប់ច្រើនក្រៃ
ដើរដេកស៊ីជិតខ្មោចក្លិនអសោចិស្អុយពេកក្រៃ    ខ្លះហើមជំស្អឹមស្លេក្ខខ្លះបាក់ដៃបែកសិរសា ។

ដើរប្រុងគ្រប់ជំហានឈានតម្រូវដានអ្នកមុន    ខុសដានមុនតែស្កុនអន្តរាយដល់ជីពជន្មា
រយៈផ្លូវដែលវិបត្តិត្រូវប្រយ័ត្នប្រាំទិវា    មួយគារុត[៣]នៃមាគ៌ាត្រូវយាត្រាអស់ប្រាំថ្ងៃ ។

អ្នកខ្លះមានកូនពីរ[៤]កើតកញ្ញើលទាំងអស់គ្នា    ខំរែកកូនលុះហើមស្មាចរយាត្រាកាត់ព្រឹក្សព្រៃ
ស្ត្រីខ្លះប្រសូតកូនទាគីឡូសាមប្រាំបី    ខ្លះរលូតកូនពីផ្ទៃលំបាកក្រៃស៊ើរមរណា ។

ខ្លះមកដល់ភូមិសាឯមកើតកូនស្រីស្រស់ប៉ប្រិម    ជីតា[៥]អរញញឹមដាក់ឈ្មោះចៅ សាឯមព្រឹក្សា
ខ្លះកើតកូននៅជើងភ្នំភ្លៀងបំព្រាំសែនវេទា    ខ្លះចោលម្ដាយចាស់ជរានាជើងភ្នំគួរស្រណោះ ។

ផ្លូវឆ្ងាយដាច់ស្រយាលយប់ដេកហាលភ្លៀងនិងខ្យល់    រងាញាក់ស៊ើរហល់រកភ្លើងគល់រលត់អស់
មូសសុចច្រើនពន់ពេកឥតបានដេកបន្តិចសោះ    សំពត់អាវទទឹកអស់គ្មានស្ងួតសោះសើមវាល់ព្រឹក។

លុះឧទ័យព្រះសុរិយាហើយនាំគ្នាចរចេញខ្ទី    ដល់ភ្នំត្បែងមានជ័យរមូលផ្ទៃញ័រគគ្រឹក
អស់កម្លាំងឈប់សម្រាកដោយលំបាកយ៉ាងពន្លឹក    ឃ្លានបាយក្រហាយទឹកញ័រល្ងិចល្ងឹកដោយហត់នឿយ។

ដើរដេកផ្ទាល់ផែនដីតាមដងព្រៃក្បែរជើងថ្នល់    ជិតពីរខែស៊ើរដាច់ខ្យល់ក្រែងមិនដល់ផ្ទះវិញឡើយ
ខោអាវថ្មីគ្មានសល់សោះដូរស៊ីអស់តាមផ្លូវហើយ    គ្មានទាំងកន្ទេលខ្នើយដេកកើយដៃអស់សង្ឃឹម ។

មិនអាចទ្រាំក៏នាំគ្នាកៀសអាត្មាប្រថុយស្លាប់    ផ្សងព្រេងស្វែងរកក័ព្វត្ដោះពាយព្យទិសបស្ចិម
ដើរវាងថ្នាំយាមផ្លូវត្រូវលុយទឹកឆ្ងាយសន្ទឹម    គេចខ្លួនផុតមានសង្ឃឹមត្ដោះបស្ចិមខំយាត្រា ។

ដល់ស្រុកស្រីសោភ័ណស្កុនដំណើរច្រើនរាត្រី    ទម្រាំដល់ជំរំថ្មីភ័យតាមផ្លូវជាច្រើនគ្រា

---

[3] ១-គារុត គឺរង្វាស់បុរាណ មានប្រវែង ២០០០ព្យាម គឺ១០០សិន ។ មួយព្យាម គឺមានចំនួនមួយកាងដៃ គឺប្រវែងបួនហត្ថ ។

[4] តាន់គិមអ៊ានខំរែកកូនពីរ ឈ្មោះនាងផង នាងភាពដែលកើតពោគកញ្ញើលទាំងពីរ។

[5] ជីតាឈ្មោះហូអ៊ីវចាយ ដាក់ឈ្មោះអោយចៅស្រី សាឯមព្រឹក្សា។

ស្នាក់នៅជាងមួយខែព្រួយឥតល្ហែរាល់ទិវា　　　អាវ៉ាសែជនពាលាវ៉ារឹបជាន់ឥតប្រណី ។

ពួកបិសាចក្នុងជំរំព្រាំខ្មែរថៃវ៉ាបំភ័ន្ត　　　បំភ័យប្រជាជនមិនឲ្យចូលទៅស្រុកថៃ
ឃាត់ឃាំងប្រជាជនទុកធ្វើឈ្នាន់សម្រាប់គែ　　　លក់អំណោយយកកម្រៃធ្វើសេដ្ឋីសម្រាប់វ៉ា ។

អន្តរជាតិរដ្ឋបាលថៃប្រោសប្រណីនាំយកឡាន　　　ទៅដឹកជនភៀសប្រាណរាប់រយឡានចូលភាព
អ្នកខ្លះមិនហ៊ានចេញដោយចាញ់កលល្បិចពួកវ៉ា　　　លុះដល់ខ្មាំងវ៉ាយប្រហារទើបនាំគ្នារត់រចល់ ។

ជនភៀសខ្លួនដូចជាចក រសាត់កកក្នុងទន្លេ　　　គ្មានទីស្ថានស្ថិតស្ថិរតែងតែរេទៅតាមខ្យល់
ផ្សងព្រេងក្នុងជលសាក្រោមបញ្ជានៃកម្មផល　　　ខ្លះត្រូវស្លាប់ខ្លះនៅសល់ខ្លះឡើងដល់ស្ថានសួគ៌ា ។

គឺស្លាប់ដោយពួកព្រៃចោរចង្រៃជាច្រើនក្រុម　　　ច្បាំងគ្នាដណ្តើមជំក្នុងជំរំក្រៅនានា
ទ័ពយួនក៏ចូលវ៉ាយភៀរយករាស្ត្របានច្រើនគ្នា　　　រុញច្រទ្បប់ទៅកម្ពុជាស្វ័យត្រានវ៉ាប្ញូន់យកអស់ ។

សម្រាតយកទាំងអាវខោគ្មានអាសូរខ្មែរដូចគ្នា　　　ផ្តាច់ផ្តិលទាំងជីវ៉ាស្លាប់ត្រៀបត្រាគ្មានស្រណោះ
ពួកប៉ុលពតក៏វ៉ាភៀរដណ្តើមគ្នាបែកខ្ញែកអស់　　　ជនកម្ពុជាត្រូវវេទនាមិនចប់សោះព្រោះអាខ្មៅ ។

គ្រោះអាសន្នក្នុងគ្រានោះសូរគ្រាប់ផ្ទុះខ្ទាំងអនេក　　　ជ្រួលច្របល់គ្មានបានដេករែកស្ពាយរត់គ្មានទីដៅ
ស្លាប់របួសច្រើនពេកណាស់ខ្លះស្លាប់កូនសូន្យទាំងចៅ　　　ទារកខ្លះស្លាប់ម៉ែឪនៅកំព្រាក្នុងស្មសាន ។

អង្គការកាកបាទខំខ្មីឃ្លាតទៅសង្គ្រោះ　　　ដឹកយកអ្នករបួសមកព្យាបាលជាច្រើនឡាន
ព្រមទាំងកូនកំព្រាអនាថាទាំងប៉ុន្មាន　　　ចូលជំរំដោយប្រោសប្រាណបានក្សេមក្សាន្តផុតពីទុក្ខ ។

ឧបត្ថម្ភគ្រឿងបរិក្ខានិងអាហារទាំងថ្នាំឆ្អិន　　　ដល់ជនឥណ្ឌូចិនដែលភៀសខ្លួនរកក្តីសុខ
ខ្លាចរបបនៃកុម្មុយនិស្តហើយគេចជៀសរត់ចោលស្រុក　　　ដើម្បីឲ្យផុតទុក្ខរត់សម្រុកចូលស្រុកថៃ ។

ទោះយួនបាញ់ស្កាត់យ៉ាងណាក៏មិនរារួញថយក្រោយ　　　គ្រាប់មីនផ្ទុះក៏ដោយរុលមិនថយទាំងប្រុសស្រី
ពុះពារប្តូរស្លាប់រស់ឆ្ពោះទៅរកលោកទីបី　　　នឹងកសាងជីវិតថ្មីរកសេរីភាពថ្លៃថ្លា ។

ខំទ្រាំច្រើនខែឆ្នាំស៊ូវេទនាកម្មក្នុងជំរំ　　　រដ្ឋបាលថៃឃួបឃុំសៀមធាក់ច្រំឥតមេត្តា
ខ្លះត្រូវវ៉ាយសម្លាប់ប្លន់យកទ្រព្យរាល់មាសា　　　ស្ទើរតែរាល់ទិវារំលោភគ្នាទាំងបំពាន ។

ជំរំឡុមភីនីទីអវសាននៃស្រុកថៃ　　　អាប់អួខ្ទាំងពេកក្រៃដេកផ្ទាល់ដីដូចតិរច្ឆាន
ទឹកជ្រាំជាំកខ្វក់ស្អុយលាមកពេញទីស្ថាន　　　មូសច្រើនខាំរំខានក្រហាយប្រាណអន្ទះសា ។

*លុះបានឡើងយន្តហោះផ្ទោះចេញផុតពីដីថៃ　　　បីដូចសត្វបក្សីរួចពីដៃព្រានពាលា*
*ហើរស្វែងរកសេរីក្នុងភពថ្មីរដ្ឋនានា　　　ខ្លះបានដល់ម៉ានីឡាតាមយថាកម្មទ្រទ្រង់ ។*

*រដ្ឋបាលហ្វីលីពីនឥតបៀតបៀនជនភៀសខ្លួន　　　គឺលាវខ្មែរនិងយួនគេថែថួនដោយផ្ចិតផ្ចង់*
*ព្រមទាំងជនជាតិគេរាប់អានខ្មែរដោយស្មោះត្រង់　　　ក្នុងជំរំមានព្រះសង្ឃលោកទ្រទ្រង់ពុទ្ធសាសនា ។*

*ខ្លះទៅម៉ាឡេស៊ីអូស្ត្រាលីស្រុកបារាំង　　　សហរដ្ឋអាមេរិកាំងមានកម្លាំងខ្លាំងមហិមា*
*ដឹកយកជនភៀសខ្លួនលាវខ្មែរយួនចូលភារា　　　ច្រើនសែននាក់ដោយគណនាឲ្យនៅជាអចិន្ត្រៃយ៍ ។*

*ឃើពុនអ៊ីតាលីស្វីសអូទ្រិសអាឡឺម៉ង់　　　បែលស៊ិកនូវែលសឺឡង់តៃវ៉ាន់ហុងកុងសឹង្ហបូរី*
*អង់គ្លេសកាណាដាឥណ្ឌូណេស៊ីប្រទេសថៃ　　　ជួយស្រង់សត្វពីជលស័យរួចពីភ័យដោយករុណា ។*

*គុណូបការៈនៃសហប្រជាជាតិ　　　អង្គការកាកបាទមានគុណធ្ងន់ដ៏មហិមា*
*បានស្រង់សត្វដែលលិចលង់សោកក្នុងមហាជលធារ　　　លាវវៀតណាមនិងកម្ពុជាដោយព្រហ្មវិហារធម៌ទាំងបួន ។*

*សូមសង្ខេបស្ទេះសេចក្តីដោយបទខ្លីត្រឹមនេះចុះ　　　ជនានុជនទាំងស្រីប្រុសចាំទុកចុះកុំភ្លេចខ្លួន*
*របបព្រៃខ្មែរក្រហមបានចារឹកទុកជាក្បួន　　　ប្រវត្តិសាស្ត្រផ្តាំតកូនដល់ចៅទួតលួតលា[6]អើយ ។*

*យើងខ្ញុំជនភៀសខ្លួនមានចំនួនប្រាំមួយនាក់[7]　　　ត្រូវសៀមដេញទម្លាក់ភ្នំដងរែករួចម្តងហើយ*
*លើកទីពីរតស៊ូទៀតចូលស្រុកសៀមមិនរាងឡើយ　　　ទម្រាំបានដល់ត្រើយត្រូវអស់ពេលពីរវស្សា ។*

*នៅក្នុងឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបមួយ　　　ជប់ប្រាំពីរផុតទុក្ខព្រួយនៅកណ្តាលខែកក្កដា*
*ត្រូវបានជិះយន្តហោះផ្ទោះចេញផុតពីម៉ានីឡា　　　ចូលមកដល់អ៊ុយអេះអាមហាប្រទេសលោកសេរី ។*

*សូមថ្លែងអំណរគុណដល់លោកប្អូនសុវណ្ណជា　　　ដែលបានរ៉ាប់ធានាយកយើងខ្ញុំដោយមេត្រី*
*ឲ្យបានមករស់នៅក្នុងប្រទេសលោកទីបី　　　បានផុតពីទុក្ខភ័យមានសេរីភាពថ្លៃថ្លា ។*

*និពន្ធដោយ*

**ឆាន់ លិ**
*ទីក្រុងឡូវែល, រដ្ឋម៉ាស្សាឈូសែត, សហរដ្ឋអាមេរិក  គ.ស. ១៩៨២*

---

[6] ត្រង់នេះគឺចង់សំដៅលើញាតិទាំងប្រាំពីរសន្តាន គឺ (១)ជីដូនជីតា (២)មាតាបិតា (៣)កូន (៤)ចៅ (៥)ចៅទួត (៦)ចៅលួត និង(៧) ចៅលា។
[7] ក្រុមគ្រួសារទាំងប្រាំមួយនាក់នោះ គឺតាទីវស៊ីមវាន់ ហៅវាន់លី, ហូបានហូ, នាងកែវ, នាងគង់, លីឈីវប៊ី, និងម៉ាតាន់ស៊ា។